ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាខេត្តប៉ៃលិន
លេខ ១៧៧៩/សជណ/បល
១៥

ប៉ៃលិន ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០១៥

## អភិបាល នៃគណៈអភិបាលខេត្ត
## ជម្រាបមក
## លោកមេឃុំ ចៅសង្កាត់គ្រប់ឃុំ សង្កាត់

**កម្មវត្ថុៈ** ស្តីពីការរៀបចំកសាងកម្មវិធីវិនិយោគឆ្នាំ ២០១៦ របស់រដ្ឋបាលឃុំ សង្កាត់ ។

**យោងៈ**
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ប្រកាសអន្តរក្រសួងលេខ២៤២៣ ប្រក ចុះថ្ងៃទី០៣ ខែ កក្កដា ឆ្នាំ២០០៧ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ស្តីពីការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគឃុំ សង្កាត់
- សេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃលេខ ៨៩០ សជណ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០០៩ ស្តីពីការរៀបចំកសាងកម្មវិធីវិនិយោគឃុំ សង្កាត់សម្រាប់ឆ្នាំ២០១០
- សេចក្តីណែនាំស្តីពី ការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ រៀបរៀងដោយក្រុមការងារអន្តរក្រសួងនាខែកក្កដា ឆ្នាំ២០០៧ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោកមេឃុំ ចៅសង្កាត់ទាំងអស់ឲ្យបានជ្រាបថាៈ កន្លងមកមានឃុំ សង្កាត់មួយចំនួន ពុំបានយកចិត្តទុកដាក់ ក្នុងការចាត់ចែងរៀបចំកសាងផែនការអភិវឌ្ឍប្រាំឆ្នាំ និងកម្មវិធីវិនិយោគប្រចាំឆ្នាំ ឬការរៀបចំធ្វើបច្ចុប្បន្នភាព កម្មវិធីវិនិយោគប្រចាំឆ្នាំរបស់ខ្លួនដោយស្មារតីទទួលខុសត្រូវ និងមានភាពជាម្ចាស់នៅឡើយ ហើយកិច្ចការនេះតែងតែមានការក្រើនរំលឹក និងរៀបចំជំនួសដោយមន្ត្រីថ្នាក់ខេត្ត ឬមន្ត្រីថ្នាក់ក្រុងស្រុក ។

ដើម្បីកែលម្អនូវបញ្ហានេះនិងដើម្បីពង្រឹងការទទួលខុសត្រូវ និងភាពម្ចាស់ការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់រដ្ឋបាលខេត្ត សូមធ្វើការណែនាំ ដូចតទៅៈ

១. ឃុំ សង្កាត់ទាំងអស់ ត្រូវចាប់ធ្វើបច្ចុប្បន្នភាពកម្មវិធីវិនិយោគសម្រាប់ឆ្នាំ២០១៦ ដោយសម្រេចឲ្យបាននូវតារាងគម្រោងវិនិយោគជាអាទិភាពរបស់ឃុំ សង្កាត់ គឺតារាង២.២ ផ្ញើទៅមន្ទីរផែនការខេត្តត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០១៥ ដើម្បីមន្ទីរផែនការខេត្តរៀបចំបញ្ចូលគម្រោងទាំងអស់នោះក្នុងប្រព័ន្ធផែនការអភិវឌ្ឍឃុំ សង្កាត់ នឹងបាន ៤

ផលិតចេញជាតារាងម៉ាទ្រិចសម្រាប់ធ្វើសិក្ខាសាលាសមាហរណកម្មផែនការក្នុងខែតុលា ឆ្នាំ២០១៥។

២. ដើម្បីទទួលបានលទ្ធផលដូចក្នុងចំណុចទី១ខាងលើ ឃុំ សង្កាត់ទាំងអស់ត្រូវធានាឲ្យមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ ក្នុងរាល់សកម្មភាព ក្នុងជំហានទីមួយៗ រួមមានដូចជា៖ ការិយាល័យជំនាញជុំវិញក្រុង ស្រុក អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាននានា និងប្រជាពលរដ្ឋ។

៣. រាល់ឯកសារដែលជាលទ្ធផលសម្រេចបានពីការអនុវត្តសកម្មភាពនៃជំហានទីមួយៗ ត្រូវរក្សាទុកដាក់ឲ្យបានសមស្រប ដើម្បីទុកសម្រាប់ចងក្រងជាសៀវភៅកម្មវិធីវិនិយោគឆ្នាំ២០១៦ និងដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់អនុម័តត្រឹមដំណាច់ឆ្នាំ២០១៥។

៤. កម្មវិធីវិនិយោគប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវថតចម្លងជូន សាលាក្រុង ស្រុក ចំនួន ០១ក្បាល មន្ទីរផែនការខេត្តចំនួន ០១ក្បាល និងទីចាត់ការផែនការ និងវិនិយោគសាលាខេត្តចំនួន ០១ក្បាល។

មន្ត្រីការិយាល័យគាំទ្រមូលដ្ឋាននៃទីចាត់ផែនការ និងវិនិយោគខេត្ត និងមន្ត្រីការិយាល័យគាំទ្រឃុំ សង្កាត់ ថ្នាក់ក្រុងស្រុក ព្រមទាំងមន្ត្រីនៃមន្ទីរផែនការខេត្ត នឹងចុះតាមដាន និងជួយគាំទ្រឃុំ សង្កាត់ ក្នុងដំណើរការរៀបចំធ្វើបច្ចុប្បន្នភាពកម្មវិធីវិនិយោគសម្រាប់២០១៦របស់ ឃុំ សង្កាត់។

អាស្រ័យហេតុនេះ សូមលោកមេឃុំ និងចៅសង្កាត់គ្រប់ឃុំ សង្កាត់ រៀបចំអនុវត្តកិច្ចការងារនេះ តាមកាលបរិច្ឆេទ មានក្នុងប្រតិទិនភ្ជាប់មកជាមួយនេះ ឲ្យមានប្រសិទ្ធិភាពខ្ពស់ ។

សូមលោកមេឃុំ និងចៅសង្កាត់គ្រប់ឃុំ សង្កាត់ ទទួលនូវការរាប់អានពីខ្ញុំ ។

អភិបាល នៃគណៈអភិបាលខេត្ត

កើត សុធា

ចម្លងជូន៖

- ក្រសួងមហាផ្ទៃ
- លេខាធិការដ្ឋាន ត.ជ.អ.ប
- ក្រុមប្រឹក្សាខេត្ត
  "ដើម្បីគោរពជូនជ្រាប"
- សាលាស្រុកសាលាក្រៅ
- សាលាក្រុងប៉ៃលិន
  "ដើម្បីសហការ"
- ឯកសារ-កាលប្បវត្តិ

# កាលវិភាគដំណើរការកសាងកម្មវិធីវិនិយោគឆ្នាំសម្រាប់២០១៦ របស់រដ្ឋបាលឃុំ សង្កាត់ ខេត្តប៉ៃលិន

| លេខកូដ | ឈ្មោះស្រុក/ក្រុង/ឃុំ/សង្កាត់ | រយៈពេល | កាលបរិច្ឆេទដំណើរការរៀបចំកសាងក្នុងឆ្នាំ២០១៦ | | | | | សម្របសម្រួលដោយ | ទូរសព្ទទំនាក់ទំនង |
|---|---|---|---|---|---|---|---|---|---|
| | | | ជំហាន១ | | | ជំហាន២ | | | |
| | | | សកម្មភាព១.១ ថ្នាក់សង្កាត់ | សកម្មភាព ១.១ថ្នាក់ភូមិ | សកម្មភាព១.១ ថ្នាក់សង្កាត់ | សកម្មភាព ២.១ គម្រោងស្នើរ | សកម្មភាព២.២ គម្រោងអាទិភាព | | |
| 2401 | ក្រុងប៉ៃលិន | | | | | | | | |
| 240101 | ប៉ៃលិន | ០៧ ថ្ងៃ | 17/08/2015 | 18/08/2015 | 19/08/2015 | 20-21/08/2015 | 24-25/08/2015 | លោក ហ៊ុច វាយោ<br>លោក ញ៉ូវ ចាន់ឌី | ០៨១ ៦០៦ ២៥៣<br>០៩៦៩៣២៣០៣០ |
| 240102 | អូរតាវ៉ៅ | ០៧ ថ្ងៃ | 17/08/2015 | 18/08/2015 | 19/08/2015 | 20-21/08/2015 | 24-25/08/2015 | លោកនួន ចាន់ធីរ៉ា<br>លោក ញ៉ូវ ចាន់ឌី | ០៩៧ ៥៥៥ ៦៥៥២<br>០៩៦៩៣២៣០៣០ |
| 240103 | ទួលល្វា | ០៧ ថ្ងៃ | 17/08/2015 | 18/08/2015 | 19/08/2015 | 20-21/08/2015 | 24-25/08/2015 | លោក គឹម ដេន<br>លោក ហ៊ាន រចនា | ០៨៧ ៥៧៨ ៥៦៥<br>០៩៦៣២៤៦៧៦៩ |
| 240104 | បរយ៉ាខា | ០៧ ថ្ងៃ | 17/08/2015 | 18/08/2015 | 19/08/2015 | 20-21/08/2015 | 24-25/08/2015 | លោក ហ្វ សារ៉ាត<br>លោក ហ៊ាន រចនា | ០១៦ ៤១៨ ៧៣៣<br>០៩៦៣២៤៦៧៦៩ |
| 2402 | ស្រុកសាលាក្រៅ | | | | | | | | |
| 240201 | សាលាក្រៅ | ០៧ ថ្ងៃ | 17/08/2015 | 18/08/2015 | 19/08/2015 | 20-21/08/2015 | 24-25/08/2015 | លោក អ៊ីង វិបុល<br>លោក វិត ចាន់ | ០៩៧ ៧៤៣៣៨៦៩<br>០៦៩ ៧០៧ ៩២៧ |
| 240202 | ស្ទឹងត្រង់ | ០៧ ថ្ងៃ | 17/08/2015 | 18/08/2015 | 19/08/2015 | 20-21/08/2015 | 24-25/08/2015 | លោល ហាម ថុល<br>លោក វិត ចាន់ | ០៩៧ ៥២២ ២៨០០<br>០៦៩ ៧០៧ ៩២៧ |
| 240203 | ស្ទឹងកាច់ | ០៧ ថ្ងៃ | 17/08/2015 | 18/08/2015 | 19/08/2015 | 20-21/08/2015 | 24-25/08/2015 | លោក ហ៊ុន ប៊ិន<br>លោកសែម សេត | ០៩៧ ២៧២១១៦៦<br>០៦៩ ៧០៧ ៩២៧ |
| 240204 | អូរអណ្ដូង | ០៧ ថ្ងៃ | 17/08/2015 | 18/08/2015 | 19/08/2015 | 20-21/08/2015 | 24-25/08/2015 | លោក សុខា ឌីនេ<br>លោក សែម សេត | ០៨១ ៧៣៧ ៧០៧<br>០៩៧ ៧៣៨៣៦៨៦ |

ប៉ៃលិនថ្ងៃទី..11...ខែសីហា ឆ្នាំ២០១៥
**នាយកទីចាត់ការផែនការ និងវិនិយោគ**

យ៉ាន អិត

ថ្ងៃទី..11....ខែសីហា ឆ្នាំ២០១៥
**រៀបចំដោយ**

ស៊ុន ម៉េងឃី